**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៥៣/១៥ ក.អ.ជ.ប្រក

ថ្ងៃព្រហស្បតិ៍ ១កើត ខែទុតិយាសាឍ ឆ្នាំមមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា គ.ស ២០១៥

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាអនាម័យជនបទ ជូនរដ្ឋបាលស្រុកគោលដៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ សន/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ៥១ អនក្រ.បកចុះ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្ម អនុក្រឹត្យលេខ៧៨ អនក្រ.បកចុះ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ចុះ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ
- បានឃើញអនុក្រឹត្យ លេខ៦៨ ចុះ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីអំពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យ លេខ ៣៦ អនក្រ.បកចុះ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង-ស្រុក
- បានឃើញអនុក្រឹត្យ លេខ ១៧២ អនក្រ.បក ចុះ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង-ស្រុក



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

Scanned by CamScanner

- បានឃើញអនុក្រឹត្យ លេខ ១៧២ អនក្រ.បក ចុះ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង-ស្រុក
- បានឃើញអនុក្រឹត្យ លេខ ២១៦ អនក្រ.បក ចុះ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញសេចក្ដីសម្រេច លេខ០១២ សសរ/គ.ជ.អ.ប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីការកំណត់ស្រុកគោលដៅសម្រាប់អនុវត្តសាកល្បង ស្ដីពីការផ្ទេរមុខងារអនាម័យជនបទ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារ “ផ្ដល់សេវាអនាម័យជនបទ” ឱ្យដល់រដ្ឋបាលស្រុកគោលដៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ ដើម្បីគ្រប់គ្រង ចាត់ចែង និង អនុវត្តសាកល្បង ក្នុងរយៈពេលពីរឆ្នាំ (០២) គឺ ចាប់ពីថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៧។

**ប្រការ ២.-**

មុខងារ “ផ្ដល់សេវាអនាម័យជនបទ” រួមមាន÷

- ការលើកស្ទួយការយល់ដឹង កែប្រែទម្លាប់ និងអភិវឌ្ឍដោយសហគមន៍ និងគ្រួសារដោយផ្ទាល់
- ការបង្កើត ជំរុញ និងសម្របសម្រួលទីផ្សារអនាម័យនៅមូលដ្ឋាន
- ការគ្រប់គ្រងទិន្នន័យស្ដីពីអនាម័យជនបទ និងទិន្នន័យពាក់ព័ន្ធទាំងអស់ក្នុងដែនសមត្ថកិច្ចរដ្ឋបាលស្រុក។

**ប្រការ៣.-**

ស្រុកគោលដៅទាំងអស់ត្រូវអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម តាមនីតិវិធី និង ទម្រង់នានាមានចែងក្នុងសៀវភៅណែនាំដែលកំណត់ដោយក្រសួងអភិវឌ្ឍន៍ជនបទ និង លេខាធិការដ្ឋាន គ.ជ.អ.ប។

**ប្រការ ៤.-**

នាយកដ្ឋានថែទាំសុខភាពជនបទត្រូវសហការជាមួយនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ និងមន្ទីរអភិវឌ្ឍន៍ជនបទនៃខេត្តទាំងពីរ ដើម្បីកំណត់ទំហំថវិកាសម្រាប់សេវាអនាម័យជនបទក្នុងស្រុក



Scanned by CamScanner

គោលដៅទាំងដប់ (១០) ដូចមានកំណត់ក្នុងសេចក្ដីសម្រេច លេខ ០១២សស/គ.ជ.អ.ប ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីការកំណត់ស្រុកគោលដៅសម្រាប់អនុវត្តសាកល្បងស្ដីពីការផ្ទេរមុខងារអនាម័យជនបទទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ ប្រភពថវិកាតាមកម្មវិធី របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

យន្តការផ្ទេរថវិកា ពីក្រសួងអភិវឌ្ឍន៍ជនបទ ទៅរដ្ឋបាលស្រុកគោលដៅ ត្រូវកំណត់ និងអនុវត្តតាមនីតិវិធី ដែលមានចែង ក្នុងកិច្ចព្រមព្រៀងអនុវត្តន៍សាកល្បងមុខងារផ្ដល់សេវាអនាម័យជនបទ រវាងក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលស្រុកគោលដៅ។

**ប្រការ ៥.-**

ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តទាំងពីរ ចាត់តាំងមន្ត្រីជំនាញ នៃការិយាល័យថែទាំសុខភាពជនបទ មន្ត្រីជំនាញពាក់ព័ន្ធ និង ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ដើម្បីជួយគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលស្រុកគោលដៅ ក្នុងរយៈពេលអនុវត្តសាកល្បងនេះ។

**ប្រការ ៦.-**

ក្នុងកំឡុងពេលអនុវត្តមុខងារសាកល្បង រដ្ឋបាលស្រុកគោលដៅមានការទទួលខុសត្រូវដូចខាងក្រោម÷

- កៀរគរ រៀបចំ និងប្រើប្រាស់ធនធានមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងបង្កើតយន្តការសម្រាប់អនុវត្តមុខងារផ្ដល់សេវាអនាម័យនៅមូលដ្ឋានរបស់ខ្លួន
- សហការជាមួយឃុំក្នុងស្រុក និងអ្នកពាក់ព័ន្ធផ្សេងទៀត រៀបចំផែនការលើកកម្ពស់អនាម័យសម្រាប់ទូទាំងស្រុក
- សហការ សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងរចនាសម្ព័ន្ធសង្គមនានា ដើម្បីអនុវត្តកិច្ចការអនាម័យជនបទឲ្យមានប្រសិទ្ធភាព
- កៀរគរធនធានសម្រាប់លើកស្ទួយសេវាអនាម័យក្នុងស្រុករបស់ខ្លួន
- ហ្វឹកហ្វឺន និង អភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលឃុំ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាប្រចាំ



Scanned by CamScanner

- ជម្រុញ និងលើកទឹកចិត្តវិស័យឯកជន ផ្ដល់សេវាអនាម័យ នៅក្នុងស្រុក រួមទាំងការអភិវឌ្ឍសមត្ថភាព និងបង្កើតភាពជាដៃគូ
- រៀបចំ និងដំណើរការប្រព័ន្ធលើកទឹកចិត្ត ដល់ប្រតិបត្តិករមូលដ្ឋានដែលអនុវត្តបានជោគជ័យ
- គ្រប់គ្រងទិន្នន័យស្ដីពីអនាម័យជនបទ និងទិន្នន័យពាក់ព័ន្ធទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
- តាមដានត្រួតពិនិត្យការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម និងកំណត់នូវវិធានការសម្រាប់កែសម្រួលយន្តការ និងវិធីសាស្ត្រអនុវត្តផ្សេងៗ
- ធ្វើរបាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាពនៃការអនុវត្តមុខងារ ជូនក្រសួងអភិវឌ្ឍន៍ជនបទតាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត។

**ប្រការ ៧.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ នាយកដ្ឋានថែទាំសុខភាពជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ និងរដ្ឋបាលស្រុកគោលដៅ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

<u>កន្លែងទទួល ៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- សាលាខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ

*"ដើម្បីជូនជ្រាប"*
- សាលាស្រុកគោលដៅ
- ដូចប្រការ៨

"ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ជា សុផារ៉ា



Scanned by CamScanner